ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

---

សំណុំរឿងរដ្ឋប្បវេណី

លេខ ១១៨

ចុះថ្ងៃទី២៧ខែមេសាឆ្នាំ១៩៩៨

សាលដីកា

លេខ : ១១៥

ចុះថ្ងៃទី២២ខែមិថុនាឆ្នាំ២០០០

## គោរពនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១_ | ឯកឧត្តម | ឌិត | មុន្ទី | ប្រធាន |
| ២_ | លោក | ប៉ែន | ស៊ុន | ចៅក្រម |
| ៣_ | លោក | ជីវ | កេង | ចៅក្រមរាយការណ៍ |
| ៤_ | លោក | ស៊ិន | ខឹម | ចៅក្រម |
| ៥_ | លោក | ប្រាក់ | គឹមសាន | ចៅក្រម |

ក្រឡាបញ្ជី

លោក ម៉េង វុធ

តំណាងមហាអយ្យការ

លោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៧១០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៩៩៧ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ឃឹម ពៅ ភេទ ស្រី អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីលំនៅភូមិឧត្តម ឃុំព្រែកខ្សាយ " ក " ស្រុកពាមរក៍ ខេត្តព្រៃវែង ។ ឪពុកឈ្មោះ ប៊ុន គី " ស " ម្តាយឈ្មោះ ឃឹម លាយ " ស " ប្តីឈ្មោះ ហេង កាំង ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ហេង សុខថា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់ក្រណាត់ មានទីលំនៅផ្ទះលេខ ២០៥E០ ផ្លូវលេខ ១៦៣ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ ហេង កាំង " ស " ម្តាយឈ្មោះ ហ៊ួច ទាង " ស " នៅលីវ ។

មានមេធាវីលោក អ៊ុក សុគន្ធ

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារចំណែកកេរ្តិ៍មរតក

បានឃើញបណ្តឹងសាទុក្ខលេខ ៩៧៦ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់អ្នកស្រី ឃឹម ពៅ បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ៧១០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១១៨ ចុះថ្ងៃទី២៧ខែមេសាឆ្នាំ១៩៩៨ របស់តុលាការកំពូល។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ១៧-០២-១៩៩២ របស់ដើមចោទឈ្មោះ អ្នកស្រី ឃឹម ពៅ ថា ខ្លួនសុំទាមទារឱ្យបែងចែកកេរ្តិ៍មរតក ដែលនៅសល់ពីខ្មោចប្តីខ្លួន ព្រោះថា ទ្រព្យសម្បត្តិផ្ទាល់ខ្លួន មានមុនពេលរៀបការ គឺចំនួន ១០ដំឡឹង លុះក្រោយពេលរៀបការហើយ ទ្រព្យសម្បត្តិរួមមានចំនួន ៣២១ ដំឡឹង ហេតុនេះ ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ផង ។

បានឃើញសាលក្រមលេខ ៤៤ " ក " ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ១៩៩៥ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ១៧-០២-៩២ របស់ដើមចោទឈ្មោះឃឹម ពៅ ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយខុស និងគតិច្បាប់ ។

២- បង្គាប់ឱ្យឈ្មោះ ឃឹម ពៅ បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្វើង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៣០០០រៀល រង្វាន់សាក្សី ២០០០រៀល បូករួម ៧០០០រៀល ប្រាក់នេះត្រូវកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៣- សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូភាគី ហើយសំរេចបើកផ្លូវឧទ្ធរណ៍រយៈពេលពីរខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៨ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៥ របស់អ្នកស្រី ឃឹម ពៅ ដែលប្តឹងជំទាស់នឹងសាលក្រមលេខ ៤៤ " ក "ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៥ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចចាត់របៀប :

១- បង្គាប់ឱ្យគូភាគីផ្តល់ភស្តុតាងបញ្ជាក់ថា ប្រពន្ធដើមរបស់ឈ្មោះ ហេង តាំង នៅមុនពេលស្លាប់ តើបានមករស់នៅលើផ្ទះលេខ ២០៩E០ ផ្លូវ១៦៣ សង្កាត់ទួលទំពូង ២ ខណ្ឌចំការមន ក្រុងភ្នំពេញ ដែរឬទេ ?

២- ចាត់ឱ្យការិយាល័យសុរិយោដីក្រុងភ្នំពេញ វាយតម្លៃផ្ទះលេខ២០៩E០ ផ្លូវ១៦៣ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន ក្រុងភ្នំពេញ តាមតម្លៃផ្សារសេរីឱ្យបានត្រឹមត្រូវ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧១០ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ របស់នាង ឃឹម ពៅ ចុះថ្ងៃទី ០៦-៤-១៩៩៥ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៤៤ " ក " ចុះថ្ងៃទី ០៥-៤-១៩៩៥ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣- ទទួលពាក្យបណ្តឹងសុំទាមទារទ្រព្យរួមរបស់នាង ឃឹម ពៅ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៤_ ទទួលពាក្យបណ្ដឹងទាមទារមរតក ឱ្យកូនទាំង ០៣នាក់ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់។

៥_ បង្គាប់ឱ្យឈ្មោះ ហេង សុខថា ប្រគល់ប្រាក់ជាមរតករបស់សពឈ្មោះ ហេង កាំង ទៅឱ្យកូននៃសពឈ្មោះ ហេង ស៊ីណែត ភេទស្រី កើតឆ្នាំ ១៩៨៥ , ហេង សុខុម ភេទប្រុស កើតឆ្នាំ ១៩៨៧ និង ហេង សុខា ភេទប្រុស កើតឆ្នាំ ១៩៩១ ក្នុងម្នាក់ៗ ចំនួន ៤.០៣៥ ដុល្លារអាមេរិក ( សរុបមរតកនៃកូនទាំងបីនាក់នេះស្មើនឹង ១២.១០៥ដុល្លារអាមេរិក ) ហើយប្រាក់នេះ ត្រូវប្រគល់ឱ្យឈ្មោះ ឃឹម ពៅ ជាម្ដាយ និង ជាអាណាព្យាបាល កាន់កាប់ និង ថែរក្សាជាប្រយោជន៍ នៃកូនជាអនីតិជនទាំងបីនាក់ខាងលើ ។ ចំណែកមរតក ដែលនៅសល់ត្រូវបានជាចំណែកស្មើគ្នាដល់កូនឈ្មោះ ហេង សុខថា និង ហេង ស៊ីណា ។

៦_ កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣០០០ រៀល គឺពន្ធឃ្លឹង និងពន្ធចុះបញ្ជីក្ដី ២.៥៥០ រៀល វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០ រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០ រៀល និង ចំណាយលើអាជ្ញាធរតុលាការ ៥០០០រៀល សរុប ១៣.០០០រៀល ។

៧_ សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងបណ្ដឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្ដឹងឧទ្ធរណ៍ បើកផ្លូវប្ដឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៤៧៦ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់អ្នកស្រី ឃឹម ពៅ បានប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ៧១០ ចុះថ្ងៃទី ០១ខែ ធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី ០៩_២_១៩៩៩ របស់ឈ្មោះ ឃឹម ពៅ

បានឃើញសារណាតប ចុះថ្ងៃទី ១៧_៨_១៩៩៩ របស់ឈ្មោះ ហេង សុខថា

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

- បណ្ដឹងសាទុក្ខរបស់ដើមចោទ ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា ។
- សាលដីកាលេខ ៧១០ ចុះថ្ងៃទី ០១_១២_៩៧ របស់សាលាឧទ្ធរណ៍ សំរេចមកនេះមានការខុសឆ្គងទាំងទំរង់ និង ទាំងគតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាសំរេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ ឃឹម ពៅ ជាដើមចោទ និងម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : មកពីសាលាឧទ្ធរណ៍ ចែកផ្ទះឱ្យមិនត្រឹមត្រូវ ដោយផ្ទះនេះជាកម្មសិទ្ធិរបស់ខ្លួនផ្ទាល់ ព្រោះផ្ទះនេះខ្លួនបានចូលមករស់នៅតាំងពីឆ្នាំ៨៥ មកម្ល៉េះ ខ្លួនសូមឱ្យបែងចែកតាមយុត្តិធម៌ ព្រមទាំងក្រុមហ៊ុនដែលចាប់ដំណើរការនៅឆ្នាំ ១៩៨៦ ពេលប្ដីស្លាប់គេបានផ្ទេរសិទ្ធិឱ្យកូនឈ្មោះឈើវ ស្រ៊ុន ក្រុមហ៊ុននេះ គឺមានដើមទុនរបស់ខ្លួនពិតប្រាកដ តាំងពីមានមួយហ៊ុនចំនួន ១៥តម្លឹង រហូតដល់មានចំនួន ១០០តម្លឹង តាំងពីពេលនោះមក មិនដែលមានការខាតបង់ទេ ។ ក្រោយមកខ្លួន បានទៅខ្ចីប្អូនថ្លៃចំនួន៥ ,២តម្លឹង ដើម្បីយកទៅថែមហ៊ុនទៀត ការចូលហ៊ុននេះគឺមិនបានសរសេរជាកិច្ចសន្យាទេ ឯហ៊ុនផ្សេងទៀត ជាអ្នកដទៃ មិនមែនជាប់សាច់ឈាមអ្វីនឹងគ្នាទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ហេង សុខថា ជាចុងចម្លើយ និងចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : ផ្ទះពិតជាមានមែន តែជាផ្ទះរបស់ឪពុក_ម្តាយ និង ជីដូនរបស់ខ្លួន ដែលបានមកស្នាក់នៅតាំងពីឆ្នាំ ១៩៧៩ មកម្លេះ ដែលមានភូមិ_ឃុំទទួលស្គាល់តាមច្បាប់ទាំងអស់ ។ ចំពោះក្រុមហ៊ុននេះ នៅដំណើរការនៅឡើយ ដោយឪពុកខ្លួនជាអ្នកឈរឈ្មោះ នៅតុលាការក្រុង គេបានហៅសមាជិកមកសួរដែរហើយ ក៏ពួកគេមកធ្វើជាសាក្សីទៀត ។ ការផ្ទេរសិទ្ធិមានមែន តែជាការរកស៊ីតូចតាចទេ បើក្រុមហ៊ុននេះមិនបានផ្ទេរឱ្យគាត់ទេ ព្រោះក្នុងក្រុមហ៊ុនគេមានលក្ខន្តិកៈរបស់គេត្រឹមត្រូវណាស់ ការផ្ទេរនេះមិនមែនផ្ទេរភាគហ៊ុនទេគឺគាត់បានផ្ទេរតែកន្ទុយក្រណាត់ដែលនៅសល់តែប៉ុណ្ណោះ ក្រណាត់នេះ គាត់ទិញហើយ ផ្ញើនៅផ្ទះគេ រួចគាត់ក៏ផ្ទេរឱ្យខ្លួនលក់បន្តទៀត ហ៊ុននេះខ្លួនមិនដឹងថាមានប៉ុន្មានទេ ខ្លួនគ្រាន់តែដឹងថាបានប្រគល់ក្រណាត់ដែលនៅសល់ឱ្យមកខ្លួនលក់ប៉ុណ្ណោះ ក្រណាត់នេះគាត់ដាក់ផ្ញើនៅក្នុងក្រុមហ៊ុន សេងឃុង ហើយគេក៏បានបញ្ជាក់ថា ក្រណាត់នៅសល់ត្រូវប្រគល់មកឱ្យខ្លួនជាកូន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោក អ៊ុក សុគន្ធ បញ្ជាក់ថា : អ្នកស្រី ឃឹម ពៅ បានរៀបអាពាហ៍ពិពាហ៍ តាំងពីយូរមកហើយ កូនក្តីរបស់ខ្ញុំបាទបានគ្រប់គ្រងកូនប្រពន្ធមុន ២នាក់ និងកូនក្រោយ ២នាក់ទៀត ការរៀបអាពាហ៍ពិពាហ៍ គឺមានច្បាប់ត្រឹមត្រូវស្របទៅតាមមាត្រា ៣៣ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ដូច្នេះផ្ទះត្រូវក្លាយជាទ្រព្យរួមសំខាន់របស់ប្តីប្រពន្ធ ពេលគាត់ស្លាប់ទៅ( ហេង កាំង ) ក៏កើតឡើងអំពីវិវាទមរតក ។ សាលាឧទ្ធរណ៍បានចែកផ្ទះឱ្យប្រពន្ធពាក់កណ្តាល ហើយពាក់កណ្តាលទៀតត្រូវបានទៅកូនឈ្មោះ ហេង សុខថា ខ្ញុំបាទយល់ឃើញថាការបែងចែកនេះមិនត្រឹមត្រូវទេ ព្រោះផ្ទះនេះអ្នកស្រី ឃឹម ពៅ បាននៅឆ្នាំ១៩៨៩ នៅពេលនោះផ្ទះនេះជាទ្រព្យសម្បត្តិរបស់រដ្ឋនៅឡើយ តាមការវាយតម្លៃផ្ទះនេះ មានតំលៃ ៥០៣០០ដុល្លា ដូច្នេះសបញ្ជាក់ថា ប្តីប្រពន្ធរស់នៅជាមួយគ្នាជាយូរមកហើយ មិនមានទ្រព្យសម្បត្តិរួមសោះនោះ មិនត្រឹមត្រូវទេ ឯចំណែកភាគហ៊ុនគឺមានតែអ្នកស្រី ឃឹម ពៅ ដែលជាកូនក្តីរបស់ខ្ញុំបាទ និង លោក ហេង កាំង ដែលពីការចូលហ៊ុនគ្នារកស៊ីនេះ ។ ដូច្នេះការអះអាងរបស់កូនក្តីខ្ញុំបាទគឺជាការត្រឹមត្រូវ សូមលោកប្រធានតុលាការកំពូលសំរេចបែងចែកទ្រព្យជាថ្មីតាមធតិយុត្តិធម៌ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៩៧៦ ចុះថ្ងៃទី ១១_១២_៩៧ របស់អ្នកស្រី ឃឹម ពៅ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា ការដែលអ្នកស្រី ឃឹម ពៅ លើកឡើងក្នុងសារណា ចុះថ្ងៃទី ០៩_០២_៩៩

ថា អ្នកស្រីទាមទារយកបន្ថែមនូវចំណែកពាក់កណ្ដាលទៀតនៃផ្ទះ ដែលតុលាការបានបែងចែកជាមរតកឱ្យកូននៃសពអ្នកស្រី ហ៊ិច ទៀង ជាភរិយាដើម នៃសពលោក ហេង កាំង នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះផ្ទះនេះជាទ្រព្យសម្បត្តិដើមរួមគ្នារបស់សពលោក ហេង កាំង និង សពអ្នកស្រី ហ៊ិច ទៀង ដែលបានកាន់កាប់មុនពេលដែលអ្នកស្រីរៀបអាពាហ៍ពិពាហ៍ជាមួយសពលោក ហេង កាំង នៅឆ្នាំ ១៩៨៥ ។

- យល់ឃើញថា ការដែលតុលាការក្រុងភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ដែលមិនបានលើកយកភាគហ៊ុននៅក្នុងក្រុមហ៊ុនក្រណាត់យីហោ សេង ហុង មកធ្វើការបែងចែកឱ្យអ្នកស្រី ឃីម ពៅ និង កូនដោយសំអាងហេតុថា សពលោក ហេង កាំង ពុំមានភាគហ៊ុននៅក្នុងក្រុមហ៊ុននេះទេ នោះជាការភាន្តច្រឡំ ពីព្រោះថា សាក្សីឈ្មោះ តាំង អេងអ៊ី ឈ្មោះ ផាន់ យ៉េន និង ឈ្មោះ សុខ សេង បញ្ជាក់ថា ពិតជាមានភាគហ៊ុនក្នុងក្រុមហ៊ុននេះ ហើយនៅពេលដែលលោក ហេង កាំង ស្លាប់ ឈ្មោះហេង សុខថា បានទៅឈរលក់ក្រណាត់ក្នុងឃ្លាំងនោះថែមទៀត ។ ម៉្យាងទៀត តាមការបកប្រែលិខិតជាភាសាចិន ចុះថ្ងៃទី១៥-១២-៩០ និង១៨-០១-៩១ ( ឯកសារ ១៩/១ , ១៩/២ ) បានបង្ហាញឱ្យឃើញថា ក្រុមហ៊ុនក្រណាត់នេះ ត្រូវបានលោក ហេង កាំង ផ្ទេរទៅឱ្យឈ្មោះ ឈឺវ ស្រ៊ុន ហៅ ហេង សុខថា មុនពេលដែលគាត់ស្លាប់មែន ។ ដូច្នេះប្រាក់អាជីវកម្មក្រណាត់នេះ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមសម្បាច់ រវាងសពលោក ហេង កាំង និង អ្នកស្រី ឃីម ពៅ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៧១០ ចុះថ្ងៃទី ០១-១២-៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវ ទាំងទំរង់ ទាំងគតិច្បាប់ ហើយលើកលែងតែចំណុចទី៣ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី

១- ទទួលបណ្ដឹងសាទុក្ខលេខ ៤៧៦ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ១៩៩៧ របស់អ្នកស្រី ឃីម ពៅ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ខ្លះ ។

២- តម្កល់ សាលដីការដ្ឋប្បវេណីលេខ ៧១០ ចុះថ្ងៃទី ០១ខែ ធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចទី៣ នៃសាលដីកានេះ ដែលត្រូវទុកជាមោឃៈ ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១១៨ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ត្រង់ចំណុចទី៣ នៃសេចក្ដីសំរេច ។

៤- រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០រៀល ដែលអ្នកស្រី ឃីម ពៅ បានបង់រួចហើយ គឺ :

- ពន្ធចុះបញ្ជីក្ដី និងពន្ធហ្លឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីភាន់ហើបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវឱ្យលោក ហេង សុខថា សងប្រាក់ចំនួន ១៩០០០រៀល នេះ ទៅអ្នកស្រី ឃីម ពៅ វិញ ។

បង្គាប់ឱ្យលោក ហេង សុខថា បង់ពន្ធសមាមាត្រ ១% លើទឹកប្រាក់ ១២.១០៥ដុល្លារអាមេរិក។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០០០ ។